# ប្រធានបណ្ណាល័យជាតិ៖ ប្រជាជនចាប់អារម្មណ៍នូវការអាន តែមិនទាន់យកការអានជាទម្លាប់

ដោយ អេង គីមហុង

*យ៉ាងហោចមានស្តង់សៀវភៅ១១០ស្តង់ ត្រៀមបង្ហាញខ្លួននៅក្នុងពិព័រណ៍សៀវភៅកម្ពុជាលើកទី៧ ដែលព្រឹត្តការណ៍នេះ នឹងចាប់ផ្តើមពីថ្ងៃទី៧ដល់ថ្ងៃទី៩ធ្នូ ក្រោមប្រធានបទ«សៀវភៅរស់ ចំណេះរីក»។ ឥទ្ធិពលនៃពិព័រណ៍សៀវភៅដែលរៀបចំតាំងតែពីឆ្នាំទី១ដល់ឆ្នាំទី៧នេះ ត្រូវបានប្រធានបណ្ណាល័យជាតិកត់សម្គាល់ថា ប្រជាជនចាប់អារម្មណ៍នូវការអាន តែមិនទាន់យកការអានជាទម្លាប់។*

ពិព័រណ៍សៀវភៅក្នុងឆ្នាំ២០១៩នេះ អ្នករៀបចំកម្មវិធីរំពឹងមានចូលរួមទស្សនាប្រមាណ៧ម៉ឺននាក់ ខណៈឆ្នាំទៅមិញពិព័រណ៍សៀវភៅមានអ្នកចូលទស្សនាប្រមាណ៥ម៉ឺននាក់។ សន្ទុះនៃអ្នកចូលទស្សនាពិព័រណ៍សៀវភៅដែលមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំជាសញ្ញាមួយបង្ហាញថា ប្រជាជនកម្ពុជារួមមាន៖ឪពុក ម្តាយ យុវជន បានចាប់អារម្មណ៍នូវការអាន។

ទន្ទឹមនឹងការចាប់អារម្មណ៍ ប្រជាជនមិនទាន់ចាប់យកការអានជាទម្លាប់នៅឡើយ ជាអ្វីដែលពិព័រណ៍សៀវភៅនៅឆ្នាំនេះនឹងបំផុសឲ្យប្រជាជនយកការអានជាទម្លាប់ប្រចាំថ្ងៃ។ នេះបើតាម លោកស្រី ខ្លូត វីបុលឡា ប្រធានបណ្ណាល័យជាតិកម្ពុជាឲ្យដឹងនៅក្នុងសន្និសីទកាសែតនៅថ្ងៃព្រហស្បតិ៍នេះ។

លោកស្រី ខ្លូត វីបុលឡា ឲ្យដឹងទៀតថា ពិព័រណ៍សៀវភៅនៅឆ្នាំនេះក៏ដូចជាឆ្នាំមុន បានផ្តោតសំខាន់ទៅលើកុមារដើម្បីឲ្យពួកគេមានទម្លាប់អានតាំងតែពីក្មេង តាមរយៈការយកចិត្តទុកដាក់ពីឪពុក ម្តាយ។ ដូច្នេះហើយទើបពិព័រណ៍សៀវភៅបានរៀបចំវេទិកាសម្រាប់កុមារដាច់ដោយឡែកតាមរយៈការគូររូបផាត់មុខនិង ការច្រៀងរាំជាដើម ដើម្បីទាញការចាប់អារម្មណ៍ពីកុមារ។

សូមបញ្ជាក់ថា ពិព័រណ៍សៀវភៅនៅឆ្នាំ២០១៩នេះ ក៏មិនខុសពីរៀងរាល់ឆ្នាំដែរគឺក្រៅពីស្តង់សៀវភៅ១១០កន្លែង នឹងមានស្តង់លក់វត្ថុអនុស្សាវរីយ៍ ការដាក់តាំងបណ្ណាល័យធម្មជាតិសម្រាប់អង្គុយអានសៀវភៅ និងការបំផុសឲ្យមានសកម្មភាពកុមារតូចៗជាដើម។ ក្នុងនោះអ្នកនិពន្ធនិងអ្នកបោះពុម្ពសៀវភៅក៏បង្ហាញវត្តមាននៅក្នុងពិព័រណ៍សៀវភៅដែរ។

បើតាមលោកស្រីប្រធានបណ្ណាល័យជាតិ ប្រមុខរដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងឧបត្ថម្ភសៀវភៅ១០ម៉ឺនក្បាលចែកជូនអ្នកទស្សនាដោយឥតគិតថ្លៃ។ ហើយតាមគម្រោងកម្មវិធីដាច់ដោយឡែកមួយទៀតនឹងរៀបចំឡើងនៅក្នុងពិព័រណ៍សៀវភៅគឺការសម្តែងល្ខោនខោល ដើម្បីអបអរដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកផ្នែកអរូបិយ៕